# សុខភាព និងសុវត្ថិភាពនៅកន្លែងធ្វើការ — ការរក្សាគម្លាត រាងកាយពីគ្នា

ការធ្វើការនៅជិតគ្នាពេកបង្កើនហានិភ័យនៃការឆ្លង COVID-19។

ចំពោះ ឱវាទសុខភាព នាពេលបច្ចុប្បន្ន គឺថាមនុស្សគ្រប់រូបរួមទាំងមនុស្សដែលនៅកន្លែងធ្វើការ ផងត្រូវតែអនុវត្តវិធានការក្នុងការរក្សាគម្លាតរាងកាយពីគ្នានៅកន្លែងណាក៏ដោយដែលអាចធ្វើបាន។

អ្នកត្រូវតែពិគ្រោះយោបល់ជាមួយបុគ្គលិក និងអ្នកតំណាងផ្នែកសុខភាព និងសុវត្ថិភាព ស្ដីពីបញ្ហាសុខភាព និងសុវត្ថិភាពទាក់ទងនឹង COVID-19។

## តើអ្វីទៅជាការរក្សាគម្លាតរាងកាយពីគ្នា?

នៅកន្លែងណាដែលអាចធ្វើបាន អ្នកត្រូវតែរក្សាចម្ងាយ 1.5 ម៉ែត្រពីអ្នកដទៃទៀត (នៅក្រៅក្រុមគ្រួសាររបស់ពួកគេ)

រដ្ឋ និងដែនដី មួយចំនួនក៏មានការរឹតត្បឹតផងដែរលើចំនួនមនុស្សដែលអាចស្ថិតនៅក្នុង កន្លែងធ្វើការនៅក្នុងមួយពេលៗ។

## តើមានវិធានការក្នុងការរក្សាគម្លាតរាងកាយពីគ្នាអ្វីខ្លះដែលអាចឱ្យនិយោជក់អនុវត្តនៅក្នុងកន្លែងធ្វើការ?

Coronavirus COVID-19 | safe work australia

## ការរៀបចំ

អ្នកអាចត្រូវការ រចនាឡើងវិញលើទម្រង់រៀបចំកន្លែងធ្វើការ និងដំណើរការងាររបស់អ្នក ដើម្បីធានាឱ្យមានការរក្សាគម្លាតរាងកាយពីគ្នា។ សូមពិចារណាលើការសម្គាល់ជាន់ ឬជញ្ជាំងដើម្បីកំណត់លក្ខខណ្ឌតម្រូវក្នុងការរក្សាគម្លាតរាងកាយពីគ្នា។

ប្រសិនបើមានការផ្លាស់ប្ដូរទម្រង់រៀបចំរូបវ័ន្តនៃកន្លែងធ្វើការ នោះទម្រង់រៀបចំរបស់អ្នក ត្រូវតែអនុញ្ញាតឱ្យបុគ្គលិកចូលចេញ និងធ្វើចលនានៅជុំវិញកន្លែងធ្វើការមានសុវត្ថិភាព ទាំងនៅក្នុងលក្ខខណ្ឌការងារធម្មតា និងនៅក្នុងភាពអាសន្ន។

## ការប្រជុំ និងការបណ្ដុះបណ្ដាល

កន្លែងដែលបុគ្គលិកប្រមូលផ្ដុំគ្នាគឺមានសារៈសំខាន់ណាស់ សូមប្រើប្រាស់ជម្រើសដែល មិនទល់មុខគ្នា ដូចជាការប្រជុំតាមទូរសព្ទ ឬការប្រជុំតាមវីដេអូ។

ប្រសិនបើជម្រើសដែលមិនទល់មុខគ្នា មិនអាចធ្វើបានទេ ត្រូវកម្រិតកំណត់រយៈពេលម៉ោងប្រជុំ និងចំនួនមនុស្ស។

ធានាឱ្យមនុស្សស្ថិតនៅយ៉ាងហោចណាស់ 1.5 ម៉ែត្រពីគ្នា។ ប្រសិនបើនៅក្នុងអគារ សូមធានាឱ្យមានប្រព័ន្ធខ្យល់ចេញចូលឱ្យបានគ្រប់គ្រាន់។

## សម្ភារបរិក្ខារនៅកន្លែងធ្វើការ

ពង្រាយគ្រឿងសង្ហារិម និងកាត់បន្ថយចំនួនបុគ្គលិកដោយប្រើប្រាស់តំបន់រួមនៅពេលមួយ ដូចជាពេលសម្រាកអាហារមានមនុស្សច្រើនគួរឱ្យភ្ញាក់ផ្អើល។

នៅក្នុងជណ្ដើរយន្ត ត្រូវធានាថាបុគ្គលិកស្ថិតនៅចម្ងាយ 1.5 ម៉ែត្រពីគ្នា ប្រសិនបើអាចធ្វើបាន។

Coronavirus COVID-19

safe work australia

ដាក់សញ្ញាអំពីការរក្សាគម្លាតរាងកាយពីគ្នា។ គេហទំព័រ Safe Work Australia មានតំណមួយចំនួនភ្ជាប់ទៅ ផ្ទាំងផ្សព្វផ្សាយ និងធនធានជាច្រើន។

សូមពិចារណាផ្តល់គ្រឿងសម្ភារជួយសម្រួលដាច់ដោយឡែក ឧទាហរណ៍បន្ទប់ទឹកដាច់ដោយឡែក សម្រាប់បុគ្គលិក និងអ្នកមកទស្សនកិច្ច។

## ការដឹកជញ្ជូន អ្នកជាប់កិច្ចសន្យា និងអ្នកមកទស្សនកិច្ច

ផ្តល់ជូនដល់មនុស្សគ្រប់គ្នាដែលចូលរួមនៅក្នុងកន្លែងធ្វើការនូវការណែនាំឱ្យបានច្បាស់លាស់ អំពីលក្ខខណ្ឌតម្រូវនានារបស់អ្នក ខណៈពេលពួកគេនៅកន្លែងធ្វើការ។ ឧទាហរណ៍ បន្តស្ថិតនៅ ក្នុងរថយន្ត ប្រើប្រាស់ទូរសព្ទដៃដើម្បីទាក់ទង និងប្រើប្រាស់ឯកសារការងារជាអេឡិចត្រូនិក។

កាត់បន្ថយឱ្យបានជាអប្បបរមានូវចំនួនបុគ្គលិកដែលទាក់ទងនឹងការដឹកជញ្ជូន និង អ្នកជាប់កិច្ចសន្យា។ ធានាឱ្យមានសម្ភារបរិក្ខារលាងដៃ ឬប្រសិនបើមិនអាចធ្វើបាន ត្រូវមានវត្ថុលាងដៃអនាម័យដែលមានជាតិអាកុលក្រោយពីធ្វើការដឹកជញ្ជូនហើយ។

## បុគ្គលិករបស់ខ្ញុំមិនអាចរក្សាគម្លាតរាងកាយពីគ្នាបានខណៈពេលកំពុងធ្វើការ តើនេះមានន័យថាពួកគេមិនអាចធ្វើការបានឬ?

វានឹងមិនអាចធ្វើបានសម្រាប់បុគ្គលិក និងអ្នកដទៃទៀតដើម្បីរក្សាចម្ងាយ 1.5 ម៉ែត្រពីគ្នាបាន ជានិច្ចនៅគ្រប់ពេលទាំងអស់នៅកន្លែងធ្វើការនោះទេ។

ប្រសិននេះជាករណីមែន សូមពិចារណាថាកិច្ចការត្រូវតែបានបញ្ចប់ ឬអាចត្រូវកំណត់ពេល ឡើងវិញ។

ប្រសិនបើកិច្ចការត្រូវតែបានបញ្ចប់ ហើយបុគ្គលិកនឹងស្ថិតនៅក្នុងទំនាក់ទំនងជិតគ្នា និយោជក់ត្រូវតែដឹកនាំធ្វើការវាយតម្លៃលើហានិភ័យដើម្បីកំណត់ថាមានអ្វីខ្លះដែលពួកគេអាចធ្វើបានក្នុងការលុបបំបាត់ចោល ឬកាត់បន្ថយឱ្យបានជាអប្បបរមានូវហានិភ័យផ្នែកសុខភាព និងសុវត្ថិភាព។

នៅពេលណាដែលអាចធ្វើបាន និងមានសុវត្ថិភាពដើម្បីធ្វើដូច្នេះ សូមពិនិត្យឡើងវិញលើកិច្ចការ និងដំណើរការនានាដែលទាក់ទងនឹងអន្តរកម្មជិតស្និទ្ធ។ កំណត់វិធីនានាដើម្បីកែប្រែកិច្ចការ និងដំណើរការទាំងនេះដើម្បីបង្កើនការនៅឃ្លាតឆ្ងាយពីគ្នា។

នៅពេលដែលមិនអាចធ្វើបាន សូមកាត់បន្ថយចំនួនម៉ោងដែលបុគ្គលិកចំណាយ ក្នុងការធ្វើទំនាក់ទំនងជិតស្និទ្ធគ្នា និងអនុវត្តវិធានការត្រួតពិនិត្យផ្សេងទៀត។

ឧទាហរណ៍៖

- កាត់បន្ថយចំនួនមនុស្សឱ្យបានជាអប្បបរមានៅក្នុងតំបន់មួយនៅពេលណាមួយ
- ចាប់ផ្តើម បញ្ចប់ និងពេលសម្រាកដោយមានមនុស្សច្រើនកុះករ
- ផ្លាស់កិច្ចការងារទៅតំបន់ផ្សេងទៀតនៃកន្លែងធ្វើការ ឬកន្លែងឆ្ងាយពីការិយាល័យ
- ដាក់បុគ្គលិកឱ្យនៅដោយឡែកទៅក្នុងក្រុមដែលដំណើរការក្នុងវេនការងារដូចគ្នា ឬនៅក្នុងតំបន់ជាក់លាក់ ដោយពិចារណាថាតើក្រុមទាំងនោះអាចមានតំបន់បរិភោគ ឬសម្ភារបរិក្ខារពេលសម្រាកផ្ទាល់ខ្លួនដែរឬអត់ និង
- ធានាថាបុគ្គលិកម្នាក់ៗមានគ្រឿងបរិក្ខារ ឬឧបករណ៍ផ្ទាល់ខ្លួនរបស់ពួកគេ។

## ការពិនិត្យឡើងវិញ និងការតាមដានជាបន្តបន្ទាប់

តាមដាន និងពិនិត្យឡើងវិញនូវការរក្សាគម្លាតរាងកាយពីគ្នាដើម្បីធានាថាវិធានការណ៍នានា កំពុងត្រូវបានអនុវត្តតាម ហើយនៅតែមានប្រសិទ្ធភាព។

ប្រសិនបើវិធានការនានាក្នុងការក្សាគម្លាតរាងកាយពីគ្នាដាក់បង្ហាញនូវហានិភ័យផ្នែកសុខភាព និងសុវត្ថិភាពថ្មីដូចជា ប្រសិនបើហានិភ័យទាំងនោះប៉ះពាល់ដល់ការធ្វើទំនាក់ទំនង ឬនាំមកនូវ

លទ្ធផលមានមនុស្សធ្វើកិច្ចការតិចពេលនោះអ្នកត្រូវការគ្រប់គ្រងហានិភ័យទាំងនោះផងដែរ។

## ព័ត៌មានបន្ថែម

សម្រាប់ព័ត៌មានបន្ថែមអំពី COVID-19 និងសុខភាព និងសុវត្ថិភាពនៅកន្លែងធ្វើការ សូមចូលទៅ គេហទំព័ររបស់ Safe Work Australia។